ទីស្តីការក្រសួងយុត្តិធម៌
លេខ ០២.សរ-៩៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សារាចរ
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
**ផ្ញើមកចំពោះ** 

**លោក ប្រធានតុលាការគ្រប់ជាន់ថ្នាក់**
**លោក អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាគ្រប់ជាន់ថ្នាក់**

*សូមជ្រាប។*

**កម្មវត្ថុ:** សេចក្តីណែនាំស្តីពីរយៈពេលដាក់រឿងក្តីដោះស្រាយទាំងរឿងរដ្ឋប្បវេណី ទាំងរឿងព្រហ្មទណ្ឌ ។
**យោង:** មាត្រា ៥១ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ និងតាមគោលការណ៍ច្បាប់ ស្តីពីវិធានចាត់ការដាក់រឿងដោះស្រាយអោយបានឆាប់ជូនប្រជារាស្ត្រ ។

កន្លងមក ក្រសួងបានកត់សម្គាល់ឃើញថា ការចាត់ការដាក់រឿងក្តីដោះស្រាយនៅមិនទាន់បានឆាប់រហ័សនៅឡើយ ។ នៅតុលាការខ្លះមានសំណុំរឿងកប់ទុកច្រើនឆ្នាំបណ្តាលឱ្យមានការប្តឹងមកក្រសួង ដើម្បីកាត់បន្ថយចំណុចខ្វះខាតបែបនេះតទៅទៀត ហើយដើម្បីតម្រង់ទិសអោយមានសុក្រឹតភាពជាអតិបរមា ក្រសួងសូមណែនាំដូចតទៅ ៖

ក-ចំពោះរឿងក្តីណា ដែលគូក្តីមានទីលំនៅស្ថិតនៅក្នុងដែនដីជាអាណាខេត្តដែនដីសមត្ថកិច្ចរបស់ខ្លួន ត្រូវចាត់ការដាក់រឿងនោះដោះស្រាយតាមកាលវិភាគរបស់ខ្លួន ក្នុងរយៈពេលមួយខែម្តងយ៉ាងយូរ ហើយចេះតែធ្វើយ៉ាងនេះ អោយបានទៀងទាត់នូវគ្រប់សំណុំរឿងទាំងអស់ជាកំណត់ ។

ខ-ចំពោះរឿងណា ដែលគូក្តីមានទីលំនៅស្ថិតនៅក្រៅអាណាខេត្តដែនដីសមត្ថកិច្ចរបស់ខ្លួន ត្រូវចាត់ការដាក់រឿងដោះស្រាយតាមកាលវិភាគរបស់ខ្លួន ក្នុងរយៈពេលពីរខែម្តងជាកំណត់ តែបើអាចចាត់ការបានឆាប់មុនពីរខែដែលកំណត់នេះជាការល្អប្រសើរ ដោយឡែករឿងអាពាហ៍ពិពាហ៍ នឹងគ្រួសារត្រូវតែគោរពតាមខ្លឹមសារនៃមាត្រា ៥១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

គ-ក្រសួងនឹងធ្វើនិយតភាព ចំពោះវិធានការនេះ នឹងវិធានការដទៃទៀតដែលមានកន្លងមកអោយបានទៀងទាត់តាមកាលវិភាគចល័តរបស់ខ្លួនអោយបានតឹងរ៉ឹង ដោយចាត់មន្ត្រីជំនាញរបស់ក្រសួងឱ្យចុះធ្វើអធិការកិច្ចតាមដានត្រួតពិនិត្យ និងវាយតម្លៃនៅតាមតុលាការនានា ហើយធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាវិន័យតាមគ្រប់យថាហេតុបន្ទាប់ពីពេលដែលសារាចរនេះបានធ្វើចរាចរដល់មូលដ្ឋាននៃតុលាការ ក្នុងរយៈពេល ២ខែ ឬ ៣ខែ រួចហើយ ។

ឃ-ចំពោះមន្ត្រីតុលាការណា ដែនបានគោរពតាមច្បាប់បទបញ្ជា និងនិយាមសីលធម៌របស់ក្រសួងបានល្អនឹងត្រូវបានទទួលការសរសើរតាមកម្រិត ។

ដូចគ្នានេះដែរ ចំពោះមន្ត្រីតុលាការណាដែលមានគំនិតធ្វេសប្រហែសដោយឆន្ទៈ ឬអឆន្ទៈ ពុំគោរពតាមច្បាប់បទបញ្ជា និងនិយាមសីលធម៌របស់ក្រសួង នឹងត្រូវទទួលការស្តីបន្ទោស ព្រមាន និងដាក់ទណ្ឌកម្មសមស្របតាមកម្រិតនៃសកម្មភាពខុសឆ្គងរបស់ខ្លួន ។

**<u>កំណត់ចំណាំ</u>** សុំឯកឧត្តមប្រធាន ឯកឧត្តមអគ្គព្រះរាជអាជ្ញា លោកប្រធាន លោកព្រះរាជអាជ្ញា ចម្លងសារាចរ នេះជូនគ្រប់លោកចៅក្រម និងគ្រប់លោកក្រឡាបញ្ជីគ្រប់ផ្នែក ក្នុងតុលាការរបស់ខ្លួនអោយបានទទួលគ្រប់ៗគ្នាកុំបីខានអោយសោះជៀសវាងការឆ្លើយថា ខ្លួនពុំបានដឹងនៅពេលក្រសួងមានវិធានការ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៦

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>

-តុលាការ អយ្យការយោធា

-ក្រុមប្រឹក្សាវិន័យរបស់ក្រសួង

-នាយកដ្ឋានបុគ្គលិក

-នាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និងរដ្ឋប្បវេណី

-ដើម្បីជ្រាប និងអនុវត្ត

-គណៈមេធាវី

-ដើម្បីជ្រាប

-ឯកសារកាលប្បវត្តិ